# ចំណាប់អារម្មណ៍

ខ្ញុំបាទ ឈ្មោះ វង្ស សុសីហា ភេទប្រុស អាយុ២០ឆ្នាំ សព្វថ្ងៃជានិស្សិតឆ្នាំទី៣ ផ្នែកប្រវត្តិវិទ្យា នៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ។

បន្ទាប់ពីបានស្តាប់ចំពោះ កម្មវិធីវិទ្យុផ្សាយសំលេងរបស់មជ្ឈមណ្ឌលឯកសារកម្ពុជារួចមក ខ្ញុំមានការចាប់អារម្មណ៍ទៅលើការផ្សាយនៅក្នុងវគ្គទី៨ នៃកម្មវិធីវិទ្យុនោះខ្លាំងណាស់។ ការចាប់អារម្មណ៍នេះដែរ ដោយសារតែនៅក្នុងការផ្សាយនៃវគ្គទី៨នេះ មានការលើកយកនូវអ្នកទោសប្រវត្តិសាស្ត្រនៃ ប្រទេសពីរផ្សេងគ្នា និងជាប្រទេសដែលធ្លាប់បានបង្កមហន្តរាយយ៉ាងធំធេង នៅក្នុងពិភពលោកនាពេលអតីតកាល។ យើងបានដឹងហើយថាប្រទេសអាឡឺម៉ង់ ដែលជាមេបញ្ជោះសង្គ្រាមលោកទាំងពីរលើកនោះ បានធ្វើទុកបុកម្នេញយ៉ាងខ្លាំងទៅដល់បណ្តាប្រទេសជាច្រើននៅក្នុងតំបន់អឺរ៉ុប។ ចំនែកឯពួកប៉ុល ពត វិញ គឺជាអ្នកទោសប្រវត្តិសាស្ត្រមួយផងដែរនៅក្នុងប្រទេសកម្ពុជា ព្រោះថាពួកប្រល័យពូជសាសន៍ទាំងអស់នេះ បានធ្វើអោយប្រជាជនកម្ពុជា ស្លាប់បាត់បង់ជីវិតយ៉ាងច្រើនលើសលប់ នៅក្នុងរបបនៃការគ្រប់គ្រងរបស់ពួកវា។ គួរបញ្ជាក់ផងដែរថា នៅក្នុងវគ្គទី៨ នៃកម្មវិធីវិទ្យុនេះបានធ្វើការប្រៀបធៀបភាពដូចគ្នារវាងមេដឹកនាំនៃប្រទេសទាំងពីរនេះ ដោយបានដឹកនាំប្រទេសក្នុងទ្រង់ទ្រាយដូចគ្នា។ ក៏ប៉ុន្តែ ចំពោះខ្ញុំបាទវិញសូមលើកយក តែបញ្ហាដែលស្ថិតនៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះ ព្រោះថាខ្ញុំបាទ គឺជាជនជាតិខ្មែរ និងចង់ដឹងយ៉ាងខ្លាំងពីប្រវត្តិសាស្ត្ររបស់ខ្លួន។ ចំណាប់អារម្មណ៍របស់ខ្ញុំ នៅក្នុងការផ្សាយនៃវគ្គទី៨ មានដូចតទៅៈ

ខ្ញុំបាទ ពិតជាមានការឈឺចាប់យ៉ាងខ្លាំងចំពោះការប្រព្រឹត្តិនូវទង្វើដ៏អាក្រក់ឃោរឃៅ ដែលមិនចេះរអែងរបស់ពួក ប៉ុល ពត មកលើប្រជាជនកម្ពុជា។ យើងឃើញថា ពួកវាបានប្រើកម្លាំងរបស់មនុស្សច្រើន ហើយចំនាយពេលវេលាធ្វើការសឹងតែគ្មានពេលសម្រាកនោះឡើយ។ ក៏ប៉ុន្តែ រាល់ការទទួលបានមកវិញនូវការហូបចុកនោះ ហាក់ដូចជាមិនមានភាពស្មើគ្នាទៅនឹងការធ្វើការនោះទេ ដែលហេតុនេះហើយ បានធ្វើអោយមនុស្សប្រឈមមុខជាមួយនឹងការថមថយកម្លាំង។ ហើយអ្វីដែលសំខាន់នោះ ប្រជាជនត្រូវបានស្លាប់យ៉ាងច្រើន ដោយសារការបង្អត់អាហារ និងការហូបចុកមិនគ្រប់គ្រាន់ក្នុងរបបដ៏ខ្មៅងងឹតនោះ។ ខ្ញុំក៏មានចំងល់ណាស់ដែរថា តើហេតុអ្វីបានជាការទទួលទិន្នផលខ្ពស់ តែបែរជាមានការអត់ឃ្លានទៅវិញ? តើពួកប៉ុល ពត យកទិន្នផលទាំងអស់នោះទៅណា? ដើម្បីអ្វី? ខ្ញុំ គិតថាប្រសិនបើទិន្នផលទាំងអស់នោះ យកមកផ្គត់ផ្គង់ចំពោះប្រជាជនទូទាំងប្រទេសវិញនោះ វាប្រាកដណាស់ថានឹងអាចធ្វើអោយប្រជាជនមានក្តីរីករាយ និងពេញចិត្តនៅក្នុងការធ្វើការងារអោយពួក ប៉ុល ពត ទៀតផង។ ខ្ញុំក៏ចង់ដឹងដែរថា តើការនាំយកទិន្នផលដ៏ច្រើនលើសលប់របស់ខ្មែរក្រហមនោះយកទៅណា ហើយវាទទួលបានអ្វីខ្លះពីការនាំចេញយ៉ាងច្រើននោះ ព្រោះថា វាជាកម្លាំងរបស់ប្រជាជន តែប្រជាជនហាក់ដូចជាមិនបានទទួលអ្វីជាដំ

កំភួនសោះឡើយពីកម្លាំងរបស់ខ្លួននោះ។ ចំងល់មួយទៀត ដែលស្ថិតនៅក្នុងអារម្មណ៍របស់ខ្លួននោះគឺ ថាតើអ្វីទៅជាភ្នំលះបង់នោះ? ហេតុអ្វីបានជាគេហៅឈ្មោះបែបនេះ? តើវាបង្កប់ទៅដោយអត្ថន័យអ្វីបន្ថែមពីលើនេះទៅ។ ជាងនេះទៅទៀត យើងបានស្តាប់លឺនូវភាពឈឺចាប់របស់ប្រជាជនដែលបានសម្ភាសន៍ ជាមួយនឹងរឿងរ៉ាវរបស់គាត់ដែល បានឆ្លងកាត់នៅក្នុងជីវិតរបស់គាត់នាពេលកន្លងមក។ វាហាក់ដូចជាមិនចង់ជឿ ដែលមនុស្សអាចធ្វើការងារបានរហូតដល់ទៅ ១២ម៉ោងក្នុងថ្ងៃ ហើយការហូបចុកវិញមានចំនួនបរិមាណតិចមិនគ្រប់គ្រាន់ផ្គត់ផ្គង់សារពាង្គកាយនោះ។

ជាចុងក្រោយ ខ្ញុំសូមអោយកម្មវិធីវិទ្យុរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា មេត្តាខិតខំស្វែងរកឯកសារអោយបានកាន់តែច្រើន ជាពិសេសនោះ គឺការផ្សាយទាក់ទងជាមួយនឹងសម្លេងពិតរបស់ប្រជាជនអោយបានច្រើន ដើម្បីអោយយើងខ្ញុំទាំងអស់គ្នាបានដឹងថា តើការរងទុក្ខរបស់ប្រជាជននៅក្នុងសម័យនោះវាយ៉ាងណា។ ព្រោះថា ខ្ញុំទាំងអស់គ្នា ដែលជាកូនចៅជំនាន់ក្រោយមិនធ្លាប់បានឆ្លងកាត់ភាពល្វីងជូរចត់ដូចជាពួកគាត់ ដើម្បីយកអ្វីដែលគាត់បានឆ្លងកាត់នោះ ធ្វើជាបទពិសោធន៍សម្រាប់ជីវិត និងកុំអោយវាកើតឡើងដដែលនៅក្នុងសង្គមរស់នៅនាពេលបច្ចុប្បន្ន និងអនាគត។ ហើយខ្ញុំសង្ឃឹមថា មជ្ឈមណ្ឌលឯកសារកម្ពុជា និងមានអ្វីដែលថ្មី និងប្លែកៗជាបន្តទៀត ដើម្បីយកមកបង្ហាញប្រាប់អោយប្រជាជនខ្មែរ ក៏ដូចជាសិស្សានុសិស្សនៅទូទាំងប្រទេសបានដឹង។ ហើយវាក៏នឹងក្លាយជាចំនេះដឹងថ្មី សម្រាប់ការសិក្សាយ៉ាងល្អប្រសើរនាពេលអនាគត់ផងដែរ។

## My Personal Impression[1]

My name is Vong Soseyha. I am 20 years old. I am a third year student majoring in History at the Royal University of Phnom Penh.

After listening to the episodes of DC-Cam's community radio program, I became very interested in the 8th episode since it raised another historical context in which mass destruction was caused. Germany was the trouble-maker in the Second World War and made serious trouble for many countries in Europe. Pol Pot's alliance was also the trouble-maker in Cambodia since they caused so many Cambodians to die during the time they in power. Interestingly, this episode made a comparison of the two countries' (Germany and Cambodia) similar policies. However, I would like to express my interest only to the Cambodian case.

I feel very sad about what Pol Pot did to Cambodians. As we see, the Khmer Rouge used the Cambodian people for human labor and they had no time for relax. The food situation was not enough to feed the workers, which led to sickness. Moreover, many people died because of starvation during the dark regime. I have one question: *Why did starvation happen while the level of food production was high?* I think that if the Khmer Rouge used all the food produced to feed the people all over the country, then people would be pleased with the regime. I also have another question*: Where was the food produced transported to? And what did the Khmer Rouge receive in return for the food, while the people seemed not to benefit from their hard labor?* I also have another question: What is Leah Bang Mountain, and how did the mountain end up with this name? On the radio program we could also listen to victims tell us about their individual stories during the regime through the interviews. To me, it is hard to believe that people could work up to 12 hours per day while food was inadequate for them.

All in all, I would like to ask DC-Cam to continue to broadcast the program, particularly the stories from victims since we want to listen to their voices. We, the younger generation, have not experienced the regime, but we would like to work together to prevent genocide from happening again. I hope DC-Cam would have more to broadcast, so that we would benefit for our study of the regime.

---

[1] Translated by Lorn Dalin; edited by Tan Sock Keng